**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: 179/បក ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី.14.ខែ.10.ឆ្នាំ២០០2

# ប្រកាស

## ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគំរោង (PMU) និងតែងតាំងនាយក និង អ្នកគ្រប់គ្រង សំរាប់អនុវត្តគំរោង ក្នុងក្របខ័ណ្ឌឥណទាននៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការបង្កើតរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើនូវច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញសេចក្តីសំរេចលេខ ១៧៩១ សសរ/អជប ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការ បែងចែក ភារកិច្ច និងការកំណត់របៀបរបបធ្វើការរបស់ថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ
- អនុស្សារណៈយោគយល់គ្នា របស់ ADB's Mission ជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានចុះហត្ថលេខានៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០២
- យោងតាមតំរូវការចាំបាច់

## សំរេច

ប្រការ១: ត្រូវបានបង្កើតឡើងនូវអង្គភាពគ្រប់គ្រងគំរោង (PMU) សំរាប់អនុវត្តគំរោងឥណទាន នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលមានស្នាក់ការនៅនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ។

ប្រការ២: តែងតាំង នាយកគំរោង (Project Director) និង អ្នកគ្រប់គ្រងគំរោង (Project Manager) សំរាប់អនុវត្តគំរោងផ្គត់ផ្គង់ទឹកជនបទ និង អនាម័យ ក្នុងខេត្តកំពង់ធំ ខេត្តកំពត និង ខេត្តពោធិសាត់ ក្នុងក្របខ័ណ្ឌឥណទាន នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **ជី សុណសា** នាយកគំរោង

២- លោក **នួន តេជ្ជនិមិត្ត** អ្នកគ្រប់គ្រងគំរោង

ប្រការ៣: មន្ត្រីដូចមានចែងក្នុងប្រការ២ មានភារកិច្ចទទួលខុសត្រូវក្នុងការដឹកនាំអនុវត្តគំរោង ក្នុងក្របខ័ណ្ឌឥណទាន នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដូចមានចែងក្នុងឯកសារគំរោង ។

ប្រការ៤: អគ្គនាយកទាំងពីរ អគ្គាធិការ ខុទ្ទកាល័យ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ ខេត្តកំពត និង ខេត្តពោធិសាត់ និង សាមីជនដូចមានចែងក្នុងប្រការ២ មានភារកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

លី – ធុជ

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ កំពត និង ពោធិសាត់
- ធនាគារអភិវឌ្ឍន៍អាស៊ី ADB

ដើម្បីជូនជ្រាប:

- ដូចមានចែងក្នុងប្រការ ៤

ដើម្បីអនុវត្ត:

- ឯកសារ-កាលប្បវត្តិ